# SPRING PARKS PRIMARY SCHOOL

*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222

spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព ចូលរួម លទ្ធផល សហគមន៏ សង្ឃឹម



## ថ្ងៃគំរោងកម្មវិធីសិក្សា:

នេះគ្រាន់តែជាការរំឭកម្តងទៀតចំពោះមាតាបិតាណាដែលបានខកខានពីសារមុន។សាលានឹងជ្រើសរើសថ្ងៃអង្គារទី២៩/៨/២០២៣ ជាថ្ងៃគំរោងកម្មវិធីសិក្សាសំរាប់ត្រីមាសទី៣។ថ្ងៃនេះបុគ្គលិកសាលាទាំងឡាយនឹងធ្វើការនៅសាលាជាមួយនឹង Berry Street សំរាប់ថ្ងៃអភិវឌ្ឍន៏វិជ្ជាជីវៈជាលើកទីពីរ។ខ្ញុំសង្ឃឹមថាថ្ងៃនេះមិនជាការលំបាកណាស់ដើម្បីរកមធ្យោបាយមើលកុមារនៅផ្ទះ។

## ពត៌មានពីគ្គលិកសាលា:

Mr Muscat នឹងសំរាកពអាទិត្យចាប់ពីថ្ងៃទី២៨/៨ដល់ថ្ងៃទី១៥/៩ក្នុងក្របខ័ណ្ឌសេវាកម្មខាងវិស័យអប់រំយូរឆ្នាំ។Mrs Edmondson ដែលបានបង្រៀនថ្នាក់Mrs Otenstein នឹងបង្រៀនជំនួសនៅពេលអវត្តមានរបស់លោកគ្រូ។

## កំណត់ប្រចាំថ្ងៃ: ១៨/៨/២០២៣

១៨/៨: ថ្នាក់ទី៣/៨ធ្វើដំណើរសិក្សានៅCranbourne Gardens
រៀនរាំនៅសាខាខាងលិច(STOMP)
១៥/៨: បាយថ្ងៃត្រង់ពិសេស
រៀនរាំនៅសាខាវ៉ាល្លី(STOMP)
១៧/៨: ថ្នាក់មូលដ្ឋានទៅលេងនៅកសិដ្ឋានមីយូណា
១៨/៨: ពិធីចេញផ្សាយសៀវភៅArdoch នៅសាខាវ៉ាល្លីនៃថ្នាក់ទី៣/៨
គោរពទង់ជាតិៈចាត់ចែងដោយថ្នាក់ទី 3/4B
និងថ្នាក់មូលដ្ឋាន FL
២១/៨: រៀនរាំនៅសាខាខាងលិច(STOMP)
២២/៨: រៀនរាំនៅសាខាវ៉ាល្លី(STOMP)
២៨/៨: ថ្ងៃស្លៀកពាក់ដោយសេរីនៃសប្តាហ៏សៀវភៅ
២៥/៨: គោរពទង់ជាតិៈចាត់ចែងដោយថ្នាក់ទី 3/4M

## ការស្ទង់មតិមាតាបិតា:

ការស្ទង់មតិប្រចាំឆ្នាំពីក្រសួងអប់រំនេះនឹងចាប់ប្រព្រឹត្តឡើងពីថ្ងៃទី៧/៨ រហូតដល់ថ្ងៃទី៨/៩ចំពោះគ្រួសារដែលបានចាប់ឈ្មោះដោយចៃដន្យដើម្បីឆ្លើយនឹងសំណួរមួយចំនួនពីមតិរបស់មាតាបិតាចំពោះបញ្ហាទាក់ទងនឹងសាលា។បើលោកអ្នកបានជ្រើសរើស,សាលានឹងផ្ញើសំបុត្រមួយជូនតាមរយៈអ៊ីម៉ែលដែលមានតំណរភ្ជាប់ទៅកាន់សំណួរស្ទង់មតិហើយមាតាបិតាអាចឆ្លើយតាមរយៈទូរស័ព្ទដែកំពុងប្រើ។ ចម្លើយទាំងឡាយនឹងបានចាត់ទុកជាអនាមិក,ហើយលទ្ធផលនឹងបានយកទៅបង្ហាញឲ្យក្រុមប្រឹក្សាជាដំបូងបង្អស់,បន្ទាប់មកនឹងផ្សាយជូនក្នុងប័ណ្ណពត៌មានសាលា។សូមជ្រើសរើសសាខាដែលកូនលោកអ្នកកំពុងរៀន,ហើយប្រើពាក្យសម្ងាត់នៃសាខានោះដើម្បីបំពេញការស្ទង់មតិ។ការបំពេញសំណួរនេះអស់រយៈពេលប្រហែល២០នាទីប៉ុណ្ណោះ។

## ថ្ងៃស្លៀកពាក់ដោយសេរីនៅទិវាសប្តាហ៏សៀវភៅនិងទិវាកីឡា:

Mr Lightfoot បានជួបប្រជុំនឹងយុវក្រុមប្រឹក្សាសាលា,ហើយបានសម្រេចថានឹងចាត់ចែង "ថ្ងៃស្លៀកពាក់ដោយសេរីនៃសប្តាហ៏សៀវភៅ" ត្រូវជាថ្ងៃព្រហស្បត៏,ទី២៨/៨។កុមារនិងបុគ្គលិកសាលាបានលើកទឹកចិត្តឲ្យស្លៀកពាក់តាមតួរអង្គក្នុងសៀវភៅ។ បន្ទាប់មកទៀតគឺថ្ងៃស្លៀកពាក់កីឡាដោយសេរី "ត្រូវជាថ្ងៃពុធទី ១៣ ខែ ៩។ថ្ងៃទាំងនេះបើកុមារអាចចូលបច្ច័យជាប្រាក់កាក់$១ឬ$២នោះពិតជាការល្អបំផុត,ហើយកុមារនឹងសម្រេចចិត្តថាតើប្រាក់ដែលរៃបាននេះនឹងផ្តល់អំណោយទៅណា។ កុមារនិងបុគ្គលិកសាលាបានលើកទឹកចិត្តឲ្យស្លៀកពាក់ឯកសណ្ឋាននៃក្រុមកីឡាណាមួយក្នុងថ្ងៃកីឡានេះ,ហើយនេះអាចជាកីឡាបាល់ឱប,បាល់ទាត់(អាចជាក្រុមកីឡាបាល់ទាត់ ជំរើសជាតិនារី(Matilda)ដែលកំពុងប្រកួតយកពានរង្វាន់ពិភពលោក(Worlld Cup)នៅម៉ែលប៊ុន)ឬកីឡាដទៃទៀត។

## ការផ្សាយសៀវភៅ Ardoch :

សិស្សថ្នាក់ទី៣និងទី៨កំពុងរវល់មមាញឹកក្នុងការសរសេរព្រាង,កែសម្រួល,និងសរសេររឿងនិទានសំរាប់កម្មវិធីសរសេរមួយដែលកុមារបានចូលរួមនឹង អារដុច (Ardoch).កុមារនឹងចេញផ្សាយសៀវវភៅមួយនៅសាខាវ៉ាល្លីនាថ្ងៃសុក្រទី១៨ នៅពេលកុមាថ្នាក់ទី៣និង៨នៃសាខាខាងលិចនឹងចាកចេញពីសាខារបស់ខ្លួននៅម៉ោង៩:១៥ព្រឹកហើយដើរទៅសាខាវ៉ាល្លីដើម្បីរួមក្នុងពិធីចេញផ្សាយសៀវភៅនេះ។ កុមារនឹងត្រឡប់មកកាន់សាខាខាងលិចវិញនៅម៉ោង១២:០០។សូមអរគុណMrs Heffernan ដែលបានចាត់ចែងកម្មវិធីដ៏ប្រពៃនេះសំរាប់កុមារសាលាយើង។

សូមឲ្យពីរសប្តាហ៏ទៅមុខនេះប្រកបដោយក្តីសុខនិងសប្បាយ។

Trish Harry :
នាយកបណ្តោះអាសន្ន




# រីករាយនឹងចូលនិវត្ត















## កម្មវិធីឆ្កែស្និទ្ធស្នាល











## ក្លិបសិល្បៈពេលបាយថ្ងៃត្រង់

នៅសាខាវ៉ាល្លីចាត់ចែងដោយសិស្សថ្នាក់ទី៦:Rosella,Khloe,Linee



## ប្រកួតកីឡារវាងសាលានានា: កីឡាបាល់បោះ

រវាងសាលាយើងនិងសាលា Springvale Rise .










ជំរាបមាតាបិតា/អាណាព្យាបាល,

ឆ្នាំនេះ,សប្តាហ៍សៀវភៅសំរាប់កុមារនឹងប្រព្រឹត្តទៀងរវាងថ្ងៃទី២១ ដល់ ២៥ ខែសីហា។ សាលាមានច្រើនរបៀបដើម្បីអបអរសាទរសប្តាហ៍ដ៏ពិសេសនេះក្នុងតារាងមាតិកាលសាលា។

ជាដំបូង,កុមារនឹងចូលរួមក្នុងសកម្មភាពខុសៗគ្នាក្នុងថ្នាក់រៀន។

បន្ទាប់មកនឹងមានការប្រណាំងប្រជែងខាងផាត់ពណ៌សំរាប់កុមារពីថ្នាក់មូលដ្ឋានដល់ទី២, ហើយការប្រណាំងប្រជែងខាងគូរគំនូរសំរាប់ថ្នាក់ទី៣ដល់ទី៦។

ទីបំផុត,ថ្នាក់ទី៦នឹងមានបញ្ចាំងបទបង្ហាញរូបភាពខ្លីៗដោយយោងទៅតាមប្រធានបទក្នុងឆ្នាំនេះមានចំណងជើងថា ,អាន, រីកលូតលាស់,បំផុសគំនិត " នៅពេលគោរពទង់ជាតិត្រូវជាថ្ងៃទី២៥/៨។បើលោកអ្នកត្រូវការចង់ដឹងច្បាស់លាស់ពីសកម្មភាពដែលកូនលោកអ្នកនឹងចូលរួមក្នុងរយៈពេលនៃសប្តាហ៍សៀវភៅនេះ,ឬលោកអ្នកមានចិត្តចង់មកជួយ,សូមមកជួបហើយសួរគ្រូរបស់កុមារ។ Ms. Wong

## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 4 | Week 5 |
|---|---|---|
| FA | Tui & Tabitha | Ishmeet & Khaubpreet |
| 1/2 A | Avi | Leo |
| 1/2 B | Zane | Katarina |
| 3/4 A | | Jaxson |
| 3/4 B | Abhi | Abbi |
| 5/6 A | Thanh | Aye Der Par |
| 5/6 B | Keinji | Fiona |
| Art | | |
| PE | Khorint | Thomas (FA) |
| Spanish | | Abchal (1&2 A) |

### VALLEY CAMPUS

| Grade | Week 4 | Week 5 |
|---|---|---|
| FL | Sophia | Peggy |
| 1/2 L | Eiri | Aleeshiya |
| 1/2 M | Richie | Zoey |
| 3/4 L | Kylie | Duong |
| 3/4 M | Zonita | Terry |
| 5/6 L | Xavijah | Vy & Chloe |
| 5/6 M | Bryceson | Tierra |
| Art | Ekin | Jenny |
| PE | Bryceson | Monika |
| Spanish | | |